# មជ្ឈមណ្ឌលឯកសារកម្ពុជា

## គម្រោងស្តីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

## រៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា

## វគ្គបណ្តុះបណ្តាលគ្រូមូលដ្ឋានលើកទី១៤ មណ្ឌលខេត្តកណ្តាល

## ៥-១០ មេសា ២០១៤

មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា មានកិត្តិយសសូមប្រកាសនូវកម្មវិធីស្តីអំពីការបង្រៀន «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» លើកទី១៤ សម្រាប់គ្រូប្រវត្តិវិទ្យា ភូមិវិទ្យា ភាសាខ្មែរ និងសីលធម៌ពលរដ្ឋ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកណ្តាល នៅថ្ងៃទី៥-១០ ខែមេសា ឆ្នាំ២០១៤ ដោយមានការចូលរួមពីសិក្ខាកាមចំនួន១០០នាក់មកពីខេត្តកណ្តាល ។ ក្នុងពិធីបើកវគ្គបណ្តុះបណ្តាល ក៏មានការអញ្ជើញចូលរួមដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិត ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៤ វេលាម៉ោង៨នាទីព្រឹក ។ វគ្គបណ្តុះបណ្តាលនេះ គឺជាជំហានឆ្ពោះទៅមុខដ៏មានសារៈសំខាន់ នៅក្នុងការផ្តល់ការអភិវឌ្ឍជំនាញដល់លោកគ្រូអ្នកគ្រូ ទៅលើខ្លឹមសារប្រវត្តិសាស្ត្រ និងវិធីសាស្ត្រក្នុងការបង្រៀន និងនៅក្នុងការជម្រុញឲ្យមានសន្តិភាព ការផ្សះផ្សា និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ។

អ្នកសិក្សាស្រាវជ្រាវពីអំពើប្រល័យពូជសាសន៍យល់ស្របថា អំពើប្រល័យពូជសាសន៍មិនទាន់ចប់នៅឡើយទេ ។ អំពើប្រល័យពូជសាសន៍ ការរំលោភសិទ្ធិមនុស្ស អំពើហិង្សានយោបាយ និងការសម្លាប់ក្នុងទ្រង់ទ្រាយធំ នៅតែបន្តកើតមាននៅជុំវិញពិភពលោក ដូចដែលកំពុងតែកើតឡើងនៅក្នុងប្រទេសស៊ូដង់ខាងត្បូង អ៊ីរ៉ាក់ ស៊ីរី ឥណ្ឌូនេស៊ី និងប្រទេសអាហ្វ្រិកកណ្តាល ។ នាពេលថ្មីៗនេះ អង្គការសហប្រជាជាតិបានព្រមានអំពីគ្រាប់ពូជនៃអំពើប្រល័យពូជសាសន៍ ដែលកំពុងត្រូវបានសាបព្រួស ហើយបានជម្រុញឲ្យមានអន្តរាគមន៍និងការផ្តល់ជំនួយមនុស្សធម៌ជាបន្ទាន់ ។

ចាប់តាំងពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យតាំងពីជាង៣៥ឆ្នាំមុន ប្រទេសកម្ពុជានៅតែបន្តតស៊ូជាមួយមរតកនៃអំពើប្រល័យពូជសាសន៍ ។ ប្រទេសកម្ពុជាមើលឃើញអំពីសារសំខាន់នៃការអប់រំជាវិធីប្រកបដោយសក្តានុពលមួយ នៅក្នុងការលើកកម្ពស់ការព្យាបាលរបួសផ្លូវចិត្ត សន្តិភាព និងការផ្សះផ្សា ។ ដើម្បីសម្រេចឲ្យបាននូវគោលដៅនេះ មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំវគ្គបណ្តុះបណ្តាលជាច្រើន ។ ចាប់តាំងពីឆ្នាំ២០០៩មក លោកគ្រូអ្នកគ្រូជាង៣ពាន់នាក់ ដែលបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យា ភូមិវិទ្យា ភាសាខ្មែរ និងសីលធម៌ពលរដ្ឋ នៅទូទាំង

ប្រទេស ទទួលបានការបណ្តុះបណ្តាលនេះ ។ ដើម្បីជាប្រយោជន៍ដល់ការពង្រីកបន្ថែមនូវលទ្ធផលនៃកម្មវិធីនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានអភិវឌ្ឍកម្មវិធីសិក្សា សម្រាប់ផ្នែកផ្សេងទៀតនៃសង្គមស៊ីវិលនិងរដ្ឋាភិបាល ។ សាស្ត្រាចារ្យសាកលវិទ្យាល័យ ដែលបង្រៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន មន្ត្រីប៉ូលិស មន្ត្រីទាហាន និងគរុនិស្សិតនៃវិទ្យាស្ថានជាតិអប់រំ ទទួលបានការបណ្តុះបណ្តាលអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងការបណ្តុះបណ្តាលទៅលើមុខវិជ្ជាជំនាញជាក់លាក់ផ្សេងៗទៀត ដែលទាក់ទងទៅនឹងអំពើប្រល័យពូជសាសន៍ ។ បន្ថែមពីលើការរីកចំរើនទាំងនេះ មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា នឹងចាប់ផ្តើមកម្មវិធីមួយបន្ថែមទៀត ដែលនឹងបណ្តុះបណ្តាលគរុសិស្ស នៅតាមមជ្ឈមណ្ឌលគរុកោសល្យភូមិភាគទាំង៦ នៅក្នុងខេត្តតាកែវ កំពង់ចាម ព្រៃវែង កណ្តាល បាត់ដំបង និងរាជធានីភ្នំពេញ ។

យុវជនកម្ពុជាជំនាន់ក្រោយ ត្រូវចេះទាញយកពិសោធន៍ពីអតីតកាលនៃប្រទេសរបស់ខ្លួនដើម្បីធ្វើជាមេរៀន ដែលអាចជួយតម្រែតម្រង់ឥរិយាបទបុគ្គល និងសីលធម៌សង្គមទូទៅ ។ ការយល់ដឹងទូលំទូលាយពីអំពើប្រល័យពូជសាសន៍នៅក្នុងរបបខ្មែរក្រហម និងប្រវត្តិនៃជម្លោះនៅក្នុងប្រទេសកម្ពុជានឹងជួយជម្រុញឲ្យយុវជនជំនាន់ក្រោយ ក្លាយទៅជាកម្លាំងចលករសម្រាប់ការផ្លាស់ប្តូរ ។ ប្រទេសកម្ពុជាចាំបាច់ត្រូវអប់រំយុវជនជំនាន់ក្រោយឲ្យក្លាយទៅជាពលរដ្ឋប្រកបដោយចំណេះដឹង ដែលអាចចូលរួមចំណែកនៅក្នុងការកសាងសង្គមមួយ ប្រកបដោយយុត្តិធម៌ សមភាព និងសន្តិភាព៕

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកលោក ម៉ម សុវណ្ណ truthsovann@dccam.org
ទូរស័ព្ទ ៖ ០១២ ៨៨៣ ៨២៨
www.dccam.org I www.cambodiatribunal.org I www.cambodiasri.org

វគ្គបណ្តុះបណ្តាលទទួលបានជំនួយទ្រទ្រង់ពី វិទ្យាស្ថានសន្តិភាពសហរដ្ឋអាមេរិក (USIP) ។ ប្រតិបត្តិការគោលទទួលបានជំនួយទ្រទ្រង់ពី ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) (២០១៣-២០១៨)